UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា

លោកស្រី **លូវីស អាបើ** (Louise Arbour) ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនឹងអញ្ជើញមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៦ ។

នេះគឺជាដំណើរទស្សនកិច្ចលើកដំបូងរបស់ឧត្តមស្នងការអ.ស.បមកកាន់ប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០២ មក ។ លោកស្រីឧត្តមស្នងការមានគំរោងចូលគាល់ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហមុនី និងជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្រៅពីនេះ លោក ស្រីឧត្តមស្នងការមានគំរោងជួបជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិមួយចំនួន ។

នៅក្នុងដំណើរទស្សនកិច្ចរយៈពេលមួយសប្តាហ៍នេះ លោកស្រីឧត្តមស្នងការនឹងជួបពិភាក្សាផងដែរជាមួយតំណាងក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា ព្រមទាំងមន្ត្រីនានានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរបបគ្រប់គ្រងរបស់ខ្មែរក្រហម ។

លោកស្រីឧត្តមស្នងការនឹងទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនៅទីក្រុងភ្នំពេញ និងប្រាសាទអង្គរវត្តផងដែរ ។

ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR ) បានដាក់ការិយាល័យមួយនៅប្រទេសកម្ពុជា ចាប់តាំងពីខែតុលា ឆ្នាំ១៩៩៣ បន្ទាប់ពីការដកចេញនៃអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាតិនៅកម្ពុជា (UNTAC) ។

**នៅពេលបញ្ចប់ទស្សនកិច្ចរបស់លោកស្រី លោកស្រីឧត្តមស្នងការនឹងធ្វើសន្និសីទសារព័ត៌មាននៅសណ្ឋាគារហ៊ីម៉ាវ៉ារី (Hotel Himawari) នៅថ្ងៃសុក្រ ទី១៩ ខែឧសភា ឆ្នាំ២០០៦ នៅវេលាម៉ោង ៩ :១៥ នាទីព្រឹក។**

*សំរាប់ប្រើប្រាស់តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន មិនមែនសំរាប់ធ្វើជាកំណត់ហេតុផ្លូវការទេ ។*

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cohchr@online.com.kh Website: http://cambodia.ohchr.org